ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ដោយអគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំស្តីអំពី
# សរុបលទ្ធផលចំណូលពន្ធប្រចាំខែ ធ្នូ ឆ្នាំ២០១៣ និង
# បូកសរុបចំណូលពន្ធប្រចាំឆ្នាំ២០១៣

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែធ្នូ ឆ្នាំ២០១៣ និងបូកសរុបចំណូលពន្ធប្រចាំឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តម **វង្ស វិសិដ្ឋ** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខណ្ឌទាំង៩នៅរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តទាំង២៣ទូទាំងប្រទេស។

ជាកិច្ចចាប់ផ្តើមគណៈអធិបតី បានសំដែងអំណរសារទរជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសំរេចបានប្រចាំឆ្នាំ២០១៣ បានលើសផែនការ ស្មើនឹង ១០១.៨% និងជម្រុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារសមាជិកអង្គប្រជុំ ដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៣។



ក្នុងខែធ្នូ ឆ្នាំ២០១៣នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣២៤,៨៥៩ លានរៀល (គិតជាដុល្លារប្រមាណ ៨១.២លានដុល្លារ)។ បើប្រៀបធៀបទៅនឹងខែធ្នូ ដូចគ្នាក្នុងឆ្នាំ២០១២ មានការកើនឡើងស្មើនិង ៥.៨%។ សរុបលទ្ធផលចំណូលពន្ធដារ

អនុវត្តបានក្នុងឆ្នាំ២០១៣ សរុបចំនួន ៣,៥២៥,៤៧៩ លានរៀល (គិតជាដុល្លារប្រមាណ ៨៨១.៤ លានដុល្លារ) ស្មើនឹង១០១.៨% នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ក្នុងនោះថវិការដ្ឋសំរេចបានចំនួនស្មើនឹង ៩៩.២% និងថវិការរដ្ឋបាលថ្នាក់ក្រោមជាតិសំរេចបានចំនួនស្មើនឹង ១២១.៤%។ បើប្រៀបធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១២ ឃើញថាក្នុងឆ្នាំ២០១៣ នេះមានការកើនឡើងចំនួនស្មើនឹងអត្រាកំណើន ១៦.១% ក្នុងនោះថវិការដ្ឋកើនឡើងចំនួនស្មើនឹង ១៦.១% និងថវិការរដ្ឋបាលថ្នាក់ក្រោមជាតិកើនឡើងចំនួនស្មើនឹង ៦.៦%។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ២០១៣ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ២៦.៨% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ២០% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ១៤.១% និង អាករពិសេសមានការកើនឡើងប្រមាណ ១៥.៧% ។

ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ២០១៣ មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ២៣.២% ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២៧.៤% ផ្នែកទូរគមនាគមន៍កើនឡើងប្រមាណ ២៦.៩% ផ្នែកផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣៤.២% ផ្នែកនីហរ័ណ-អាហរ័ណកើនឡើងប្រមាណ ១៤.៤% ស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៣៤.២% ផ្នែកផលិតសម្លៀកបំពាក់ ៤៤.៥% ផ្នែកដឹកជញ្ជូននិងទេសចរណ៍ ៣៣.៩% អាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ៨១.៧% សណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ២០.៤% លក់គ្រឿងយន្តស្មើនឹង ២៣៦.៦% ផលិតម្ហូបអាហារស្មើនឹង ៥៣.៧% និងផ្នែកផលិតគ្រឿងអេឡិចទ្រិចនិងអេឡិចត្រូនិច ស្មើនឹង ៣៦.៣%។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-របាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋាន សាខាពន្ធដារខេត្ត-ខណ្ឌ ស្តីពីការប្រមូលចំណូលពន្ធប្រចាំខែធ្នូឆ្នាំ ២០១៣ និងប្រចាំឆ្នាំ២០១៣ II-ទិសដៅសម្រាប់អនុវត្តបន្តឆ្នាំ២០១៤ និងIII-បញ្ហាផ្សេងៗ។

ដើម្បីគ្រប់គ្រងចំណូលពន្ធដារឱ្យមានស្ថេរភាពលើវិស័យមួយចំនួន ដែលមានសក្តានុពលចំណូលច្រើន អគ្គនាយកដ្ឋានពន្ធដារមានគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៤ ដូចខាងក្រោម៖

- ពង្រឹងការគ្រប់គ្រងលើការប្រមូលពន្ធនិងអាករឲ្យមានប្រសិទ្ធភាពនិងតម្លាភាព ជាពិសេសពន្ធតែមប្រ៍ និងអាករពិសេសលើទំនិញនិងសេវាកម្មមួយចំនួន។ល។
- រៀបចំធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យារបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធឱ្យកាន់តែមានភាពល្អប្រសើរជាងមុន។
- រៀបចំធ្វើបច្ចុប្បន្នភាពការចុះបញ្ជីរបស់ក្រុមហ៊ុនដែលត្រូវជាប់អាករលើតម្លៃបន្ថែម ដើម្បីឱ្យមានសុវត្ថិភាព និងគ្រប់គ្រងឱ្យបានល្អប្រសើរជាងមុន។
- រៀបចំណែនាំឱ្យអង្គភាពក្រៅរាជរដ្ឋាភិបាលមកចុះបញ្ជី ដោយតម្រូវឱ្យអង្គភាពក្រៅរដ្ឋាភិបាលទាំងអស់ដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា បំពេញកាតព្វកិច្ចច្បាប់ស្តីពីសារពើពន្ធ មកចុះបញ្ជីពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ និងប្រកបដោយតម្លាភាព។
- បន្តបណ្តុះបណ្តាល ពង្រឹងសមត្ថភាពរបស់មន្ត្រីពន្ធដារ ពង្រឹងវិន័យ និងក្រមសីលធម៌ ក្នុងគោលបំណងលុបបំបាត់អំពើអសកម្មនានា និងអំពើពុករលួយ។ អប់រំ និងផ្លាស់ប្តូរផ្នត់គំនិតរបស់មន្ត្រីពន្ធដារ ពីការគិតថាជាអ្នកត្រួតត្រាមកជាអ្នកបម្រើសេវាដ៏ល្អជូនអ្នកជាប់ពន្ធ។ បន្តការកែទម្រង់ស៊ីជម្រៅរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ និងតម្លាភាព ព្រមទាំងការគោរពច្បាប់។

- រៀបចំប្រព័ន្ធលើទឹកចិត្ត ដល់មន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ស្របទៅតាមគោលការណ៍សមធម៌ ដោយផ្អែកលើអភិបាលអភិក្រមលទ្ធផលនៃការងារជាមូលដ្ឋាន(Performance Based)។

ជាកិច្ចបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលដែលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំ បន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ ខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និង បទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសំរេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។







**អគ្គនាយកដ្ឋានពន្ធដារ**